# IV. អនុសាសន៍

តាមរយៈលទ្ធផលវង្វាយតម្លៃខាងលើ និងដើម្បីបង្កើនល្បឿនកំណែទម្រង់វិស័យអប់រំអោយសម្រេចបានតាម "គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍" និង "គោលដៅអប់រំសម្រាប់ទាំងអស់គ្នា" កត្តាដែលសំខាន់នោះគឺ :

- ត្រូវធានាថា កម្មវិធីកំណែទម្រង់ក្នុងវិស័យអប់រំ និងសកម្មភាពជាអាទិភាពទាំងអស់ពិតជាមានផលប៉ះពាល់វិជ្ជមានជាអតិបរមា ជាពិសេសលើផ្នែកគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ។
- ពង្រឹងវិន័យការងារ និងការគ្រប់គ្រងពេលវេលាបំពេញការងារ ពិសេសការអនុវត្តម៉ោងបង្រៀន និងពេលឈប់សំរាកថ្ងៃបុណ្យនានា និងវិស្សមកាលអោយមានប្រសិទ្ធភាពខ្ពស់ ។
- លើកកំពស់លក្ខខណ្ឌបំពេញការងាររបស់មន្ត្រី ដើម្បីបង្កើនប្រសិទ្ធភាពការងារដែលកំពុងអនុវត្ត ដោយរួមបញ្ចូលការកែលំអប្រាក់បៀវត្សរ៍ ការតំឡើងឋានៈតួនាទីដោយផ្អែកលើគុណភាពការងារ ការផ្តល់រង្វាន់ផ្អែកលើគុណសម្បត្តិការងារដែលបំពេញបាន ការទ្រទ្រង់ដល់ការសាងសង់ផ្ទះស្នាក់នៅរបស់គ្រូបង្រៀន និងការផ្តល់រង្វាន់លើកទឹកចិត្តសំរាប់តំបន់ដាច់ស្រយាលនិងជួបការលំបាក ។
- ដើម្បីសំរេចបានគោលដៅរយៈពេលមធ្យមរបស់ការងារអប់រំសំរាប់ទាំងអស់គ្នា ក្រសួងអប់រំត្រូវចាត់អាទិភាពដោយសង្កត់ធ្ងន់លើការកែលំអអត្រាចូលរៀនថ្មីថ្នាក់ទី១នៃបឋមសិក្សា និងអត្រាឡើងថ្នាក់នៅក្នុងភូមិសិក្សាបឋមសិក្សាទាំងមូល ដែលជាមូលដ្ឋានសំរាប់ឱ្យសិស្សបន្តការសិក្សាទៅមុខទៀតបានល្អ។
- បង្កលក្ខណៈសម្បត្តិក្នុងការបំពេញការងារ និងការផ្តល់ព័ត៌មានអោយបានសមស្រប និងទាន់ពេលវេលាដល់ថ្នាក់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀន តាមរយៈការកសាងសមត្ថភាព និងការអភិវឌ្ឍស្ថាប័ន ។
- ធ្វើការសិក្សាអំពីស្ថានភាពសិស្សបោះបង់ការសិក្សា និងកំណត់លក្ខណៈវិនិច្ឆ័យអោយបានច្បាស់លាស់ រួមនឹងការសិក្សាស្រាវជ្រាវអំពីបញ្ហាដទៃទៀតដែលកំពុងកើតមានក្នុងប្រព័ន្ធអប់រំទាំងមូល ដើម្បីធ្វើសេចក្តីសំរេចចិត្តប្រកបដោយប្រសិទ្ធភាព ពិសេសដើម្បីបន្តផ្តល់ហិរញ្ញប្បទានដល់កម្មវិធីទាំងឡាយឱ្យមានដំណើរការ ។
- ពិនិត្យឡើងវិញ និងកែលំអការកត់ត្រាតួលេខ ឬការស្រង់ស្ថិតិសិក្សា និងប្រព័ន្ធគ្រប់គ្រងពត៌មានអប់រំគ្រប់ផ្នែកដើម្បីជៀសវាងភាពមិនប្រក្រតី ដែលធ្វើអោយប៉ះពាល់ដល់លទ្ធផលបំពេញការងារវិស័យអប់រំ ។
- ធានាឱ្យបាននូវប្រសិទ្ធភាព នៃការសំរេចគោលនយោបាយអប់រំទាំងឡាយ ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា គោលដៅអភិវឌ្ឍសហសត្សវ៏កម្ពុជា ។ ក្រសួងអប់រំ យុវជន និងកីឡា គប្បីពិនិត្យឡើងវិញអំពីការកំណត់ដៅក្នុងផែនការទាំងនោះ ដើម្បីធានាឱ្យបាននូវលក្ខណៈប្រជាធិបតេយ្យក្នុងផែនការ ប្រាកដនិយមជាក់លាក់ អាចអនុវត្តបាន និងមិនស្រមើស្រមៃលោភលន់ហួសហេតុ ដែលមិនមានការលើកទឹកចិត្តដល់ប្រតិបត្តិករក្នុងវិស័យអប់រំទាំងមូល រួមទាំងថ្នាក់កណ្តាល ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និងសាលារៀន ។